**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៨៩៤/០២ សហវ/វសហ

# សេចក្តីជូនដំណឹង

១៥៧

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានកិត្តិយសជំរាបជូនដំណឹងដល់មន្ត្រីរាជការនៃក្រសួងសាមី និង ក្រសួង/ស្ថាប័ននៃរាជរដ្ឋាភិបាលជ្រាបថា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានតំរូវការជ្រើសរើសមន្ត្រីរាជការ ដើម្បីបណ្តុះបណ្តាលជំនាញ " ពន្ធដារ " នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់បំរើការងារក្នុងនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំនួន ៨៥ រូប ។

មន្ត្រីរាជការ ដែលមានបំណងចូលរៀន ដើម្បីធ្វើការក្នុងនាយកដ្ឋាននេះ នឹងត្រូវជ្រើសរើស តាមរយៈការប្រលងប្រជែង និង ដោយមានកាយសម្បទាមាំមួន និងមានលក្ខណៈសម្បត្តិដូចតទៅ:

១. មានសញ្ញាប័ត្របរិញ្ញាប័ត្រឡើងទៅ ផ្នែកដែលពាក់ព័ន្ធសេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬ ច្បាប់

២. មានចំណេះដឹងផ្នែកភាសាអង់គ្លេស និង បច្ចេកវិទ្យាពត៌មាន (មុខវិជ្ជាដែលត្រូវប្រលង)

៣. មានចំណេះដឹងទូទៅក្នុងផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និង គណនេយ្យ (មុខវិជ្ជាដែលត្រូវប្រលង)

៤. មានអាយុមិនលើស ៣៥ ឆ្នាំ ។

បេក្ខជនទាំងពីរភេទ ដែលមានក្របខ័ណ្ឌមកពីក្រសួង/ស្ថាប័នផ្សេង ត្រូវមានការយល់ស្របផ្ទេរក្របខ័ណ្ឌពីក្រសួង/ស្ថាប័នរបស់ខ្លួនជាមុន សំរាប់មកបំពេញការងារក្នុងក្របខ័ណ្ឌនៃនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ការផ្ទេរក្របខ័ណ្ឌជាក់ស្តែង នឹងត្រូវធ្វើឡើងបន្ទាប់ពីបានបញ្ចប់ការសិក្សា នៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាស្ថាពរ ។

សេចក្តីដូចបានជំរាបជូនខាងលើ ប្រសិនបើ មន្ត្រីរាជការនៃក្រសួងសាមី និងក្រសួង/ស្ថាប័ននៃរាជរដ្ឋាភិបាល មានបំណងចូលរួមការប្រលងនេះ សូមអញ្ជើញមកដាក់ពាក្យ និង បំពេញបែបបទនៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទប់លេខ ២៧ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០២ ។ មន្ត្រីរាជការ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចរៀបរាប់ខាងលើ នឹងត្រូវបានអញ្ជើញមកចូលរួមប្រលង ដើម្បីជ្រើសរើសចូលរៀន ។ កម្មវិធី កាលបរិច្ឆេទនៃការប្រលង និងបញ្ជីរាយនាមបេក្ខជនដែលត្រូវប្រលង នឹងបិទផ្សាយជូននៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨